# ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

តាមរយៈបេសកកម្មនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមវាយតម្លៃឯករាជ្យបានចុះស្រាវជ្រាវដល់មូលដ្ឋានដោយមានការជួបសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួននៅថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់អំពីកម្រិតយល់ដឹងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីបំពេញការងារនៅថ្នាក់ក្រោមជាតិពាក់ព័ន្ធការបំពេញការងារតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ជាលទ្ធផល ក្រុមវាយតម្លៃបានសង្កេតឃើញថា ថ្នាក់ដឹកនាំ និងមន្ត្រីនៅថ្នាក់ក្រោមជាតិហាក់នៅមិនទាន់យល់ច្បាស់អំពីគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងរបៀបរបបថ្មីនៃការគ្រប់គ្រង ស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ច្បាប់រៀបចំអង្គការ) នៅឡើយទេ បើទោះបីច្បាប់នេះ បានដាក់ឱ្យប្រើប្រាស់តាំងពីឆ្នាំ២០០៨ និង២០០១ ព្រមទាំងមានការបណ្តុះបណ្តាលជាបន្តបន្ទាប់យ៉ាងណាក្តី។ ក្នុងន័យនេះ គណៈកម្មការបានសំរេចដកស្រង់បទឧទ្ទេសនាមគន្លឹះរបស់ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅក្នុង*វគ្គបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលជាន់ខ្ពស់* ដែលរៀបចំឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារអាំងទែកង់ទីណង់តាល់ រាជធានីភ្នំពេញ មកចុះផ្សាយឡើងវិញសម្រាប់អ្នកពាក់ព័ន្ធធ្វើការសិក្សាបន្ថែមអំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។



ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ច្បាប់រៀបចំអង្គការ បានកំណត់ឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នីមួយៗជានីតិបុគ្គល ដែលមានស្វ័យភាពក្នុងការគ្រប់គ្រង ចាត់ចែងកិច្ចការនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងគោលបំណងបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។ ជោគជ័យនៃបេសកកម្មនេះ មួយផ្នែកធំ គឺអាស្រ័យលើការដឹកនាំ គ្រប់គ្រងរបស់ថ្នាក់ដឹកនាំនៅរដ្ឋបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**គោលការណ៍នៃការគ្រប់គ្រង**

មាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា “*រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍*

*នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។*
ផ្អែកតាមស្មារតីនេះ ចាប់តាំងពីឆ្នាំ២០០៩មក ប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញ និងដាក់ឱ្យដំណើរការ ដោយឈរលើគោលការណ៍នៃ *រដ្ឋបាលឯកភាព* និង *ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ*។

*រដ្ឋបាលឯកភាព* សំដៅលើការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និង ធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗនោះមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាព នូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

*ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ* សំដៅលើកិច្ចអភិវឌ្ឍដែលត្រូវធ្វើឡើងស្របទៅតាមគោលការណ៍ទាំង៨ ដូចមានកំណត់នៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គោលការណ៍ទាំង៨នេះរួមមាន ភាពជាតំណាងសាធារណៈ ស្វ័យភាពមូលដ្ឋាន ការពិគ្រោះយោបល់ និងការចូលរួម ការឆ្លើយតប និងគណនេយ្យភាព ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន ការលើកស្ទួយសមធម៌ តម្លាភាពនិងសុចរិតភាព ព្រមទាំងវិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។ គោលការណ៍ទាំង៨នេះ មានទំនាក់ទំនងផ្សាភ្ជាប់គ្នា និងជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមក។ ភាពទន់ខ្សោយក្នុងការអនុវត្តសមាសធាតុណាមួយ ឬមួយចំនួន ឬការខកខានមិនបានដាក់បញ្ចូលនូវសមាសធាតុណាមួយ ឬមួយចំនួនទៅក្នុងកិច្ចដំណើរការនៃការរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ នឹងជះឥទ្ធិពលមិនល្អដល់សមាសធាតុផ្សេងទៀត ដែលអាចធ្វើប៉ះពាល់ដល់ចីរភាពនៃដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជារួម ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដែលរៀបចំឡើងវិញស្របតាមច្បាប់រៀបចំអង្គការ តម្រូវឱ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗមានក្រុមប្រឹក្សាដែលជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន មានសិទ្ធិអំណាចនិងធនធាន ព្រមទាំងស្វ័យភាពក្នុងការគ្រប់គ្រងចាត់ចែងធនធានទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងលក្ខណៈប្រកបដោយតម្លាភាព សុចរិតភាព និងបរិយាប័ន្ន។

**តួអង្គសំខាន់។**

ដើម្បីសម្រេចបាននូវប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ដែលឆ្លើយតបទៅនឹងគោលការណ៍ដូចខាងលើ ច្បាប់រៀបចំអង្គការបានកំណត់ឱ្យមានអង្គសំខាន់ពីរនៅក្នុងស្ថាប័នអភិបាលកិច្ចនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ។ អង្គមួយគឺ“ក្រុមប្រឹក្សា” ដែលកើតឡើងពីការបោះឆ្នោត និងបំពេញការងារដើម្បីប្រជាពលរដ្ឋ ក្នុងនាមប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អង្គមួយទៀតគឺជា “គណៈអភិបាល” ដែលរួមមានអភិបាល និងអភិបាលរងមួយចំនួន។ គណៈអភិបាលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល ដើម្បីទៅបំពេញការងារជាមួយក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

អង្គទាំងពីរបំពេញការងារដោយឡែកពីគ្នា ប៉ុន្តែមានលក្ខណៈបំពេញឱ្យគ្នា និងគាំទ្រគ្នាទៅវិញទៅមកក្នុងគោលបំណងរួមគឺ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងបរិយាប័ន្ន សំដៅរួមចំណែកធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋានរបស់ខ្លួន។ ក្នុងនាមប្រជាពលរដ្ឋ និងដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន ក្រុមប្រឹក្សាមានតួនាទីជាអ្នកចាត់ចែងកិច្ចការចាំបាច់នានានៅមូលដ្ឋាន តាមរយៈការប្រើប្រាស់សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ទោះជាយ៉ាងនេះក្តី ក្រុមប្រឹក្សាពុំមានសិទ្ធិចាត់ចែងកិច្ចការជាក់ស្តែងនានា ដើម្បីអនុវត្តសេចក្តីសម្រេចទាំងនោះឡើយ។ ជាទូទៅ ក្រុមប្រឹក្សាបំពេញតួនាទី ភារកិច្ចរបស់ខ្លួន តាមរយៈការតាមដាន ពិនិត្យ ពិភាក្សា និងធ្វើសេចក្តីសម្រេចលើកិច្ចការចាំបាច់នានានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ។ ការគ្រប់គ្រង ចាត់ចែងអនុវត្តជាក់ស្តែងនូវរាល់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា គណៈអភិបាលជាអ្នកទទួលខុសត្រូវរ៉ាប់រង ក្នុងនាមក្រុមប្រឹក្សាដោយមានការគាំទ្រពីមន្ត្រីរាជការ ដែលបំពេញការងារនៅតាមអង្គភាពនានាក្នុងរចនាសម្ព័ន្ធនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗរបស់ខ្លួន។ ក្នុងន័យនេះ គណៈអភិបាលគឺជាអ្នកទទួលខុសត្រូវ និងជាអ្នកដឹកនាំដ៏សំខាន់នៅរដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ ក្នុងការធានាថា រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានយកទៅអនុវត្តដោយពេញលេញ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

**តើគណៈអភិបាលត្រូវបំពេញការងារដូចម្តេច ដើម្បីដឹកនាំចាត់ចែងកិច្ចការនានានៅមូលដ្ឋានឱ្យមានប្រសិទ្ធភាព?**

**ក.ត្រូវឈ្វេងយល់ពីតួនាទី ភារកិច្ចរបស់គណៈអភិបាល**

ជាក្រឹត្យក្រម អភិបាល អភិបាលរងនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗត្រូវស្គាល់ និងឈ្វេងយល់ឱ្យបានច្បាស់លាស់អំពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធានាថារាល់ទង្វើ និងសកម្មភាពរបស់ខ្លួនត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។ យោងតាមច្បាប់រៀបចំអង្គការ និងអនុក្រឹត្យលេខ២១៥ និង ២១៦ ដែលចែងអំពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តួនាទី ភារកិច្ចចម្បងៗរបស់គណៈអភិបាលរួមមានដូចខាងក្រោម៖

*ការផ្តល់យោបល់ជូនក្រុមប្រឹក្សា៖* ក្រុមប្រឹក្សាបំពេញការងាររបស់ខ្លួន តាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា។ ម្យ៉ាងទៀត សមាជិកក្រុមប្រឹក្សានីមួយៗ គឺជាអ្នកនយោបាយនៅមូលដ្ឋាន ដែលមានប្រភពមកពីច្រើនមជ្ឈដ្ឋាន។ ហេតុនេះ ដើម្បីធានាឱ្យការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាធានាបាននូវគុណភាព និងប្រសិទ្ធភាព គណៈអភិបាល ដោយមានការគាំទ្រពីមន្ត្រីបច្ចេកទេសនៅក្នុងអង្គភាពរបស់ខ្លួន ត្រូវខិតខំរិះរកគ្រប់មធ្យោបាយដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាក្នុងលក្ខណៈប្រកបដោយវិជ្ជាជីវៈ និងងាយយល់ ដើម្បីធានាឱ្យកិច្ចប្រជុំរបស់ក្រុមប្រឹក្សាអាចពិនិត្យ ពិភាក្សា ពិគ្រោះយោបល់ និងធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ និងមានអត្ថន័យប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈឆ្លើយតប។

*ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា៖* ជាគោលការណ៍ រាល់កិច្ចការនានាដែលអនុវត្តដោយគណៈអភិបាល ត្រូវមានការសម្រេចជាមុនពីក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ កិច្ចការទាំងនេះអាចជាកិច្ចការដែលស្នើឡើងដោយក្រុមប្រឹក្សាផ្ទាល់ ឬដោយគណៈអភិបាល ហើយទទួលបានការសម្រេចពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ប៉ុន្តែក្នុងករណីចាំបាច់បន្ទាន់គណៈអភិបាលក៏អាចចាត់វិធានការដោះស្រាយ ឬធ្វើសកម្មភាពជាមុន ទើបរាយការណ៍ជូនក្រុមប្រឹក្សាជាក្រោយ។ ឧទាហរណ៍ ការចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយបញ្ហាទឹកជំនន់ អគ្គីភ័យ..ជាដើម។ល។ ទន្ទឹមនេះ គណៈអភិបាលត្រូវឈ្វេងយល់ថា *គណៈអភិបាល ឬអភិបាល ដែលបានសម្រេច ឬបានអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេចឬសកម្មភាពនោះ ពុំមានសុពលភាពឡើយ* (មាត្រា១៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ក្រៅពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គណៈអភិបាលក៏មានតួនាទីអនុវត្តកិច្ចការដែលបានទទួលប្រតិភូកម្មពីរដ្ឋាភិបាល ក្នុងនាមក្រសួង ស្ថាប័នផងដែរ។

*ការរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សា៖* គណៈអភិបាល ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សាក្នុងការអនុវត្តការងាររបស់ខ្លួន។ ហេតុនេះ គណៈអភិបាលមានកាតព្វកិច្ចត្រូវរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សា អំពីលទ្ធផលនៃការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា អំពីបញ្ហាហិរញ្ញវត្ថុ និងអំពីសកម្មភាពដទៃទៀតរបស់គណៈអភិបាល។ របាយការណ៍នេះ ត្រូវព្យាយាមរៀបចំឱ្យមានលក្ខណៈងាយយល់ ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ ពិភាក្សា និងផ្តល់អនុសាសន៍។

*ការពង្រឹងការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព៖* របៀបរបបគ្រប់គ្រងនេះអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗធ្វើការកៀរគរ ប្រមូលផ្តុំ និងប្រើប្រាស់ធនធានពីគ្រប់មជ្ឈដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញការផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានដែលមានលក្ខណៈសមាហរណកម្មកាន់តែប្រសើរ។ អភិបាល ក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនិងក្នុងនាមជាតំណាងក្រសួង ស្ថាប័ននៅក្នុងដែនសមត្ថកិច្ច ត្រូវខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីសម្របសម្រួល និងណែនាំមន្ទីរ អង្គភាពជំនាញឱ្យចូលរួមអនុវត្តដោយសកម្ម ក្នុងការលើកកម្ពស់ការគ្រប់គ្រងតាមបែបរដ្ឋបាលឯកភាព សំដៅបញ្ចៀសការធ្វើផែនការជាន់គ្នា ក៏ដូចផ្លាស់ប្តូរព័ត៌មាន ដកបទពិសោធន៍ពីគ្នាទៅវិញទៅមក និងលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្ស និងថវិកាដែលមាននៅក្នុងមូលដ្ឋាន។

**ខ.ត្រូវផ្លាស់ប្តូរទម្លាប់ និងឥរិយាបថការងារ**

ចាប់ពីឆ្នាំ២០០៩ ការគ្រប់គ្រងនៅរដ្ឋបាលគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិបានចាប់ផ្តើមរបត់មួយថ្មី ដែលទាមទារឱ្យថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងរបស់មន្ទីរ អង្គភាពខ្សែបណ្តោយនៃក្រសួង ស្ថាប័ននានា ត្រូវផ្លាស់ប្តូរទម្លាប់ និងឥរិយាបថនៅក្នុងការបំពេញការងាររបស់ខ្លួន ដោយត្រូវខិតខំបន្សាំខ្លួនទៅនឹងរបៀបរបបគ្រប់គ្រងថ្មីតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅក្នុងការបំពេញការងារប្រចាំថ្ងៃ ទម្លាប់ និងឥរិយាបថជា "អ្នកផ្តល់សេវា" ត្រូវផ្លាស់ប្តូរមកជា"អ្នកបម្រើសេវា" ដោយត្រូវប្រកាន់

ខ្ជាប់នូវកាយវិការរាក់ទាក់ ទន់ភ្លន់ និងស្វាគមន៍ចំពោះប្រជាពលរដ្ឋដែលមកទទួលសេវាកម្មនានា។ ទន្ទឹមនេះ គណៈអភិបាល ត្រូវយកចិត្តទុកដាក់ក្នុងការផ្តួចផ្តើមគំនិត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបម្រើសេវានានាឱ្យមានលក្ខណៈកាន់តែឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ជាពិសេសការលើកកម្ពស់ការបម្រើ*សេវាតម្រូវការ* និង*សេវាសំណូមពរ* នៅមូលដ្ឋាន ក៏ដូចការឆ្លើយតបទៅនឹងសំណូមពរផ្សេងៗទៀតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើរទន្ទឹមនឹងកិច្ចខិតខំអភិវឌ្ឍមូលដ្ឋានលើគ្រប់វិស័យ សំដៅរួមចំណែកលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋាន។

**គ.យកចិត្តទុកដាក់លើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រី បុគ្គលិក**

ស្ថាប័នមួយអាចបំពេញបេសកកម្មដោយជោគជ័យ និងរលូនបាន លុះត្រាណាបុគ្គលិកនៅក្នុងស្ថាប័ននោះមានសមត្ថភាព និងឆន្ទៈក្នុងការបំពេញការងារ។ ហេតុនេះ ការយកចិត្តទុកដាក់អភិវឌ្ឍសមត្ថភាព និងលើកកម្ពស់ឆន្ទៈរបស់បុគ្គលិកដោយថ្នាក់ដឹកនាំ គឺជាកិច្ចការសំខាន់នៅក្នុងការដឹកនាំ គ្រប់គ្រងស្ថាប័ន ក្នុងន័យនេះ ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗគួរយកចិត្តទុកដាក់លើកិច្ចការមួយចំនួនដូចខាងក្រោម៖

- ធ្វើជាគំរូល្អសម្រាប់មន្ត្រី បុគ្គលិកនៅក្នុងរដ្ឋបាលរបស់ខ្លួន
- យកចិត្តទុកដាក់ និងឈ្វេងយល់អំពីសុខទុក្ខ និងការលំបាករបស់មន្ត្រី បុគ្គលិកម្នាក់ៗ
- លើកទឹកចិត្តតាមគ្រប់រូបភាព ដល់មន្ត្រី បុគ្គលិកដែលខិតខំបំពេញការងារ និងមន្ត្រីបុគ្គលិកមានស្នាដៃឆ្នើម
- កែលម្អបរិយាកាសកន្លែងការងារឱ្យមានលក្ខណៈទាក់ទាញ និងផាសុកភាព
- រៀបចំនិងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពមន្ត្រី បុគ្គលិកជាប្រចាំ។

សរុបមក ជោគជ័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា គឺអាស្រ័យលើកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនៅមូលដ្ឋាន និងការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរួមគ្នាបម្រើសេវាជូនប្រជាពលរដ្ឋ និងអភិវឌ្ឍមូលដ្ឋានប្រកបដោយភាពឆ្លើយតប ប្រសិទ្ធភាព តម្លាភាព សមធម៌ និងបរិយាប័ន្ន សំដៅសម្រេចបាននូវចក្ខុវិស័យនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ៕

# ភាពជាអ្នកដឹកនាំ៖ បទពិសោធន៍ខេត្តបាត់ដំបង

*"ពេលថ្ងៃត្រូវតែស្អាត មានសោភ័ណភាព សណ្តាប់ធ្នាប់ល្អ ពេលយប់ត្រូវតែមានសុវត្ថិភាព មានភ្លើងបំភ្លឺ"*

*ឯកឧត្តម **ច័ន្ទ សុផល** អភិបាលខេត្តបាត់ដំបង*



ឯកឧត្តម ចំន្ទ សុផល អភិបាលខេត្តបាត់ដំបង

ជាខេត្តចំណាស់មួយ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ខេត្តបាត់ដំបង មានធនធានធម្មជាតិ និងវប្បធម៌ជាច្រើនដែលជាអំណោយផលដ៏គាប់ប្រសើរ សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត អ្នកទេសចរជាតិ និងអន្តរជាតិ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងខេត្ត។

ផ្អែកតាមស្ថិតិជំរឿនប្រជាពលរដ្ឋឆ្នាំ១៩៩៨ ខេត្តបាត់ដំបង មានចំនួនប្រជាពលរដ្ឋប្រមាណ ៧៩៣,១២៧នាក់។ បច្ចុប្បន្នចំនួនប្រជាពលរដ្ឋបានកើនឡើងដល់ ១,១៤៦,១៧៤នាក់ (ឆ្នាំ២០១៤) ជាមួយនឹងអត្រាកំណើនប្រមាណ ២.២៥%ក្នុងមួយឆ្នាំ។ អត្រាកំណើននេះ មានសន្ទុះលឿនបើប្រៀបធៀបទៅនឹងអត្រាកំណើនទូទាំងប្រទេស ដែលមានប្រមាណ ១.៦%ក្នុងមួយឆ្នាំ(ឆ្នាំ២០១៤)។ ទាំងនេះជាសក្ខីភាពបញ្ជាក់ថា ខេត្តបាត់ដំបងមានលក្ខណៈទាក់ទាញច្រើន សម្រាប់ប្រជាពលរដ្ឋរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត។ ភាពទាក់ទាញរបស់ខេត្តបាត់ដំបង មិនត្រឹមតែស្រូបទាញនិងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យមករស់នៅក្នុងខេត្តតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើនមកទស្សនា និងលំហែកាយនៅក្នុងខេត្តបាត់ដំបងទៀតផង។ ក្នុងឆ្នាំ២០១៤ ភ្ញៀវទេសចរជាតិ និងអន្តរជាតិមានចំនួន៥២៦,៩៩៧នាក់ កើនឡើង ១០.៦១%ធៀបទៅនឹងឆ្នាំ២០១៣(៤៧៥,៩៨៦នាក់) ដែលអត្រាកំណើននេះ គឺមានប្រមាណ១.៥ដង នៃអត្រាកំណើនទេសចរទូទាំងប្រទេស។

ទន្ទឹមនឹងអត្រាកំណើនប្រជាពលរដ្ឋ និងអ្នកទេសចរជាតិ និងអន្តរជាតិដ៏គួរឱ្យកត់សម្គាល់ខាងលើ ការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គម និងសន្តិសុខ សណ្តាប់ធ្នាប់ នៅក្នុងខេត្តបាត់ដំបងរឹតតែមិនអាចមើលរំលងបាន។ បើយើងធ្វើដំណើរតាមបណ្តោយស្ទឹងសង្កែ នៅពេលល្ងាចម៉ោងប្រមាណជា៤:០០រសៀល យើងសង្កេតឃើញមានមនុស្សយ៉ាងច្រើនកុះករ ទាំងក្មេង ចាស់ ប្រុស ស្រី ជាតិខ្មែរ និងបរទេស កំពុងហាត់ប្រាណក្រោមរូបភាពផ្សេងៗគ្នា និងអង្គុយ

លំហែកាយក្នុងទឹកមុខស្រស់ស្រាយសប្បាយរីករាយ នៅតាមបណ្តោយសួនច្បារដ៏ស្រស់ស្អាតស្របតាមដងស្ទឹងសង្កែ ចាប់តាំងពីទីតាំងសាលាខេត្តបាត់ដំបង រហូតដល់ស្ពានថ្មថ្មី។ សកម្មភាពបែបនេះ លោកអ្នកនៅតែអាចបន្តទស្សនារហូតដល់ពេលងងឹត ដែលនៅ



សួនច្បារសម្តេចក្រឡាហោម ស ខេង

ពេលនោះរឹតតែមានភាពស្រស់ស្អាតជាមួយនឹងការបំភ្លឺភ្លើងអគ្គិសនីគួរឱ្យទាក់ទាញ។ លើសពីនេះទៀត បើយើងធ្វើដំណើរចេញផុតពីបរិវេណនេះ ហើយជិះកម្សាន្តតាមផ្លូវនានានៅក្នុងខេត្ត បណ្តាញផ្លូវក្រាលកៅស៊ូខ្វាត់ខ្វែងប្រកបដោយសោភ័ណភាពអមដោយបង្គោលភ្លើងអគ្គិសនី សំណង់បុរាណដែលមានរចនាបថប្រកបដោយភាពទាក់ទាញមិនជិនណាយ រួមទាំងសំណង់ទំនើបៗ ក្រុមហ៊ុនតូចធំ សកម្មភាពអាជីវកម្មមមាញឹក មន្ទីរពេទ្យ មណ្ឌលសុខភាព សាលារៀន សាកលវិទ្យាល័យ រមណីយដ្ឋាន វាលស្រែល្វឹងល្វើយខៀវខ្ចី និងប្រព័ន្ធធារាសាស្ត្រជាច្រើន នឹងទាក់ទាញអារម្មណ៍របស់យើង ដែលធ្វើឱ្យយើងមិននឿយណាយ មានតែភាពរីករាយស្រស់ស្រាយក្នុងដំណើរកម្សាន្តរបស់យើង។

ជារួម វឌ្ឍនភាពខេត្តបាត់ដំបងក្នុងរយៈពេលជិតពីរទសវត្សរ៍កន្លងមកនេះ បានប្រែក្លាយទឹកដីខេត្តបាត់ដំបងពីសមរភូមិប្រយុទ្ធដ៏ស្រួចស្រាល់ និងខ្ទេចខ្ទាំបំផុត មកជាដែនដីមួយដែលមានការអភិវឌ្ឍរីកចំរើនដែលនឹកស្មានមិនដល់ ជាទឹកដីប្រកបដោយសក្តានុពល និងមានប្រជាជនដែលឧស្សាហ៍ព្យាយាម មានគំនិតច្នៃប្រឌិត និងរស់រាយរាក់ទាក់បំផុត។ ជាក់ស្តែង នៅក្នុងពិធីសម្ពោធជាផ្លូវការគម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ***សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** ក៏បានលើកសរសើរអំពីការដឹកនាំ និងអភិវឌ្ឍនៅខេត្តបាត់ដំបងនេះដែរ ដោយសម្តេចលើកឡើងថា "....*សំណាងហើយអ្នកបាត់ដំបងនោះ បានទទួលអភិបាលខេត្តដ៏ល្អមួយ សូមអបអរសាទរ*......"។

ដើម្បីឈ្វេងយល់បន្ថែមអំពីការដឹកនាំ និងការអភិវឌ្ឍខេត្តបាត់ដំបងឱ្យកាន់តែច្បាស់ កាលពីខែកក្កដា ឆ្នាំ២០១៦ ក្រុមការងារបានចុះជួបជាមួយឯកឧត្តម **ច័ន្ទ សុផល** អភិបាលខេត្តបាត់ដំបង ក៏ដូចជាក្រុមប្រឹក្សា មន្ត្រីរាជការ ប្រជាពលរដ្ឋ និងសិស្ស-និស្សិតនៅក្នុងខេត្ត។ នៅក្នុងឱកាសនោះ ឯកឧត្តមអភិបាលខេត្ត បានលើកឡើងអំពីសមិទ្ធផលសំខាន់ៗរបស់ខេត្តបាត់ដំបង ក៏ដូចជាកិច្ចការគន្លឹះមួយចំនួនក្នុងការដឹកនាំខេត្តរបស់ឯកឧត្តម។

ពាក់ព័ន្ធការអភិវឌ្ឍខេត្ត ឯកឧត្តមបានលើកឡើងថា ខេត្តមានបណ្តាញផ្លូវក្រាលកៅស៊ូទៅកាន់គ្រប់ខេត្តនៅជុំវិញ និងបណ្តាក្រុង ស្រុករបស់ខេត្ត ដោយក្នុងនោះ ផ្លូវទៅកាន់ឃុំក្នុងខេត្តប្រមាណ ៩០% បានក្រាលកៅស៊ូរួចរាល់។ មិនតែប៉ុណ្ណោះជារៀងរាល់

ឆ្នាំ ខេត្តបានយកចិត្តទុកដាក់ជួសជុល ស្តារ និង កសាងបណ្តាញផ្លូវក្នុងខេត្ត ឱ្យកាន់តែមានភាពល្អ ប្រសើរឡើង និងមានវិសាលភាពដល់តំបន់ជនបទ ដាច់ស្រយាលថែមទៀត។ ក្រៅពីនេះ នៅមាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ដែលចូលរួម លើកកម្ពស់សោភ័ណភាព និងសុខុមាលភាព របស់ប្រជាពលរដ្ឋក្នុងខេត្តបាត់ដំបង មានដូចជា ការស្តារ និងកសាងសួនច្បារនៅតាមបណ្តោយ មាត់ស្ទឹងសង្កែ រួមទាំងការដំឡើងសម្ភារបរិក្ខារហាត់ ប្រាណការដំឡើងចង្កៀង-អំពូល ការដាក់ធុងសំរាម នៅតាមទីសាធារណៈ និងការកែលម្អប្រព័ន្ធលូ ជាដើម។ ជាមួយគ្នានេះ ដើម្បីសម្រួល និងធានា សណ្តាប់ធ្នាប់ចរាចរណ៍ ខេត្តបាននិងកំពុងដំឡើង ភ្លើង និងស្លាកសញ្ញាចរាចរណ៍ជាច្រើនគោលដៅ ផងដែរ។ ទន្ទឹមនេះ ខេត្តក៏បានយកចិត្តទុកដាក់យ៉ាង ខ្លាំងផងដែរ ទៅលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ដែលជាសរសៃឈាមនៃការអភិវឌ្ឍវិស័យកសិកម្ម ដែលជាវិស័យស្នូលសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចខេត្ត បាត់ដំបង។ ជាក់ស្តែង បច្ចុប្បន្នខេត្តកំពុងមមាញឹក ក្នុងការសាងសង់ប្រព័ន្ធធារាសាស្ត្រកង្ហត ដែល អាចមានសមត្ថភាពស្រោចស្រពលើផ្ទៃដីស្រែក្នុង ក្រុង ស្រុកចំនួន៥ គឺក្រុងបាត់ដំបង ស្រុកបាណន់ ស្រុកសង្កែ ស្រុកគាស់ក្រឡ និងស្រុកមោងឫស្សី។

ដើរទន្ទឹមនឹងការខិតខំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចសង្គម ដើម្បីទ្រទ្រង់ និងជំរុញការអភិវឌ្ឍ សេដ្ឋកិច្ចសង្គមនៅក្នុងខេត្ត ឯកឧត្តមអភិបាលខេត្ត ក៏បានបន្ថែមទៀតថា ក្នុងមួយរយៈកន្លងមកនេះខេត្ត បាត់ដំបង បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង លើការជួយដោះស្រាយបញ្ហាប្រឈម នានា ដែល កើតមានឡើងចំពោះប្រជាពលរដ្ឋទូទៅ កសិករ អាជីវករ ធុរជន ក៏ដូចជាវិនិយោគិននៅក្នុងខេត្ត ដែលកត្តាទាំងនេះបានបង្កបរិយាកាសអនុគ្រោះ និងអំណោយផលគួរឱ្យទាក់ទាញ សម្រាប់ការជំរុញ វឌ្ឍនភាពលើវិស័យជាច្រើននៅក្នុងខេត្ត ជាពិសេស វិស័យកសិកម្ម កសិឧស្សាហកម្ម ពាណិជ្ជកម្ម និង ទេសចរណ៍។



សំណង់ស្វាក់ទឹកកម្ពុជា-កូរ៉េ

ក្រៅពីកិច្ចខិតខំប្រឹងប្រែងខាងលើ ឯកឧត្តម ក៏បានគូសបញ្ជាក់បន្ថែមថា កត្តាជោគជ័យដែល ខេត្តទទួលបានកន្លងមក មួយផ្នែកធំគឺអាស្រ័យ ដោយខេត្តរក្សាបានល្អប្រសើរនូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមនៅក្នុងខេត្ត។

ក្រៅពីជួបជាមួយឯកឧត្តមអភិបាលខេត្ត ក្រុម ការងារក៏បានឆ្លៀតពេលជួបសម្ភាសន៍ជាមួយ ប្រជាពលរដ្ឋ សិស្ស និស្សិត អាជីវករ និងមន្ត្រីរាជការ មួយចំនួនផងដែរ។ ជារួម ក្រុមគោលដៅដែលក្រុម ការងារបានជួបសម្ភាសន៍ សុទ្ធតែបានលើកឡើងពី ការកោតសរសើរចំពោះសមិទ្ធផលនានា ដែល រដ្ឋបាលខេត្តបានខិតខំអភិវឌ្ឍកន្លងមក ជាពិសេស

អ្នកទាំងនោះមានការរីករាយ និងពេញចិត្តយ៉ាងខ្លាំងចំពោះការខិតខំប្រឹងប្រែងរបស់រដ្ឋបាលខេត្តក្នុងការរៀបចំឱ្យមានបរិស្ថានប្រកបដោយផាសុកភាព ក្នុងនោះមានដូចជាការរៀបចំឱ្យមានសួនច្បារស្រស់ស្អាត ការដាំដើមឈើតាមមាត់ស្ទឹង កន្លែងហាត់ប្រាណ បង្គន់អនាម័យ ធុងសំរាមសាធារណៈ និងមានភ្លើងបំភ្លឺនៅពេលយប់ជាដើម។

សក្ខីកម្មខាងលើនេះ ជាការឆ្លុះបញ្ចាំងឱ្យឃើញពីភាពជោគជ័យរបស់ខេត្តបាត់ដំបង ក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តបាត់ដំបងទាំងមូល ជាពិសេស ឯកឧត្តមអភិបាលខេត្ត។ ឆ្លើយតបទៅនឹងសំណួររបស់ក្រុមការងារ ឯកឧត្តមអភិបាលខេត្ត បានលើកឡើងអំពីគោល-ការណ៍ និងយុទ្ធ-សាស្ត្រជាគន្លឹះក្នុងការជំរុញឱ្យឯកឧត្តមទទួលបានជោគជ័យសំរេចសមិទ្ធិផលក្នុងការដឹកនាំដូចខាងក្រោម៖

***១.កិច្ចសហការ***

កិច្ចសហការល្អបាននាំមកនូវការចូលរួមប្រកបដោយអត្ថន័យពីអ្នកពាក់ព័ន្ធទាំងអស់ដែលកត្តានេះបានក្លាយជាធនធានដ៏ចម្បងនៅក្នុងការអភិវឌ្ឍខេត្តបាត់ដំបង។ ឯកឧត្តមអភិបាលខេត្តបានលើកឡើងនូវគន្លឹះដើម្បីទទួលបានកិច្ច-សហការល្អថា យើងចាំបាច់ត្រូវព្យាយាមធ្វើការ



សកម្មភាពចូលរួមសម្អាតបរិស្ថាន

ដោយអត់ធ្មត់ ស្មោះត្រង់ និងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដែលតាមរយៈនេះ យើងនឹងអាចទទួលបានមកវិញនូវទឹកចិត្តដ៏ស្មោះសរពីអ្នកទាំងនោះ ក្នុងការសហការ និងចូលរួមជាមួយយើងដោយអស់ពីចិត្តពីថ្លើម។ ជាក់ស្តែង ឯកឧត្តមអភិបាលខេត្ត តែងព្យាយាមស្វែងយល់អំពីសុខទុក្ខរបស់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងនោះមានដូចជា ការចុះទៅសួរសុខទុក្ខដល់ទីស្នាក់អាស្រ័យរបស់ប្រជាពលរដ្ឋ សប្បុរសជន ឬវិនិយោ-គិន។ ម្យ៉ាងទៀត តាមការជួបសម្ភាសន៍ជាមួយក្រុមប្រឹក្សា ក៏ដូចជា មន្ត្រីរាជការនៅក្នុងសាលាខេត្ត បានឱ្យដឹងថា ពេលខ្លះទោះបីពុំមានការអញ្ជើញ ក៏ឯកឧត្តមអភិបាលខេត្តឆ្លៀតពេលទៅចូលរួមដែរ ប្រសិនបើទទួលបានព័ត៌មានពីកម្មវិធីនោះ។ លើសពីនេះទៀតនៅពេលឯក-ឧត្តមធ្វើដំណើរតាមផ្លូវ ឯកឧត្តមតែងចុះសួរសុខទុក្ខ និងចូលបច្ច័យតាមសទ្ធានៅពេលឆ្លងកាត់ទីតាំងដែលមានធ្វើពិធីបុណ្យរបស់ប្រជាពលរដ្ឋនៅតាមភូមិជាដើម។

ដោយឡែក ពាក់ព័ន្ធនឹងកិច្ចសហការជាមួយមន្ទីរអង្គភាពជំនាញជុំវិញខេត្ត ឯកឧត្តមបានលើកឡើងថា ដើម្បីផ្តល់សេវា និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ក៏ដូចការអភិវឌ្ឍខេត្តប្រកបដោយ

ប្រសិទ្ធភាព កម្លាំង និងធនធានរបស់រដ្ឋបាលខេត្តតែមួយគឺមិនអាចរ៉ាប់រងទាំងស្រុងបានឡើយ។ ហេតុនេះ ចាំបាច់ណាស់ដែលយើងត្រូវខិតខំ សម្របសម្រួល និងសហការគ្នាឱ្យបានល្អប្រសើរដើម្បីកៀរគរ និងប្រើប្រាស់ធនធានទាំងអស់ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខេត្តឱ្យចំទិសដៅ និងអស់លទ្ធភាព សំដៅរួមគ្នាឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែង កាលពីរដូវរាំងស្ងួតកន្លងមកនេះ ខេត្តបានសម្របសម្រួលដឹកនាំ មន្ទីរកសិកម្ម មន្ទីរធនធានទឹក និងសហការជិតស្និតជាមួយអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីរួមគ្នាដោះស្រាយបញ្ហារាំងស្ងួតដែលកើតឡើងដោយបាតុភូតធម្មជាតិ ដោយបញ្ចៀសបានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅ ក៏ដូចផលិតផលកសិកម្មរបស់ប្រជាពលរដ្ឋ។

២.*ការបើកទូលាយ*

**"គ្រប់ការងារទាំងអស់ត្រូវបើកទូលាយ ទទួលយកមកចាត់ចែងអនុវត្ត"** នេះជាការលើកឡើងរបស់ឯកឧត្តមអភិបាលខេត្ត។ ឯកឧត្តមយល់ឃើញថា គ្រប់កិច្ចការទាំងអស់ទោះតូច ឬធំយ៉ាងណាក្តី សុទ្ធសឹងតែមានសារប្រយោជន៍ និងបម្រើឱ្យសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដូចគ្នា។ ក្នុងន័យនេះ ឯកឧត្តមតែងតែខិតខំឈ្វេងយល់អំពីតម្រូវការ ក៏ដូចជាបញ្ហាប្រឈមនានា ដែលកើតមានឡើងទាំងនៅក្នុងក្របខ័ណ្ឌនៃរដ្ឋបាលខេត្តផ្ទាល់ ក៏ដូចជាកើតឡើងចំពោះប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលនានា ជាដើម។ ក្នុងឱកាសជួបជាមួយតំណាងក្រុមប្រឹក្សាខេត្ត បានឱ្យដឹងថាឯកឧត្តមអភិបាលខេត្តតែងមានវត្តមានជាប្រចាំ នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាទាំងសាមញ្ញ និងវិសាមញ្ញ លើកលែងតែពេលដែលឯកឧត្តម ត្រូវចេញទៅបំពេញបេសកកម្មនៅក្រៅខេត្ត។ ក្រៅពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឯកឧត្តមតែងរៀបចំឱ្យមានកិច្ចប្រជុំគណៈអភិបាលជាញឹកញាប់ ដើម្បីពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់អំពីកិច្ចការនានានៅក្នុងខេត្ត ទន្ទឹមនឹងការរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយមន្ត្រីរាជការទាំងអស់នៅក្នុងសាលាខេត្ត ដើម្បីផ្តល់ឱកាសឱ្យមន្ត្រីរាជការទាំងនោះមានយោបល់ និងលើកឡើងនូវបញ្ហាប្រឈមនានានៅក្នុងការបំពេញការងាររបស់ខ្លួន ក៏ដូចជាផ្តល់ការណែនាំ និងតម្រង់ទិសដល់មន្ត្រីរាជការទាំងអស់



កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត

ឱ្យខិតខំបម្រើសេវាជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។ ទន្ទឹមនេះ ឯកឧត្តមអភិបាលខេត្ត ក៏បានលើកឡើងទៀតថា នៅក្នុងការធ្វើសេចក្តីសម្រេចលើកិច្ចការអ្វីមួយ ឯកឧត្តមតែងតែព្យាយាមឈរលើគោលការណ៍ឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ មិនថាអ្នកទាំងនោះជាសមាជិកក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីរាជការ ប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ឬអង្គការ

សង្គមស៊ីវិលនោះឡើយ ពោលគឺមិនអត្តនោម័ត ដោយធ្វើអ្វីមួយដោយមិនបានស្តាប់មតិយោបល់ឬពិគ្រោះយោបល់ឱ្យបានគ្រប់ជ្រុងជ្រោយនោះឡើយ។

៣.*ការចុះផ្ទាល់*

នេះជាចំណុចពិសេសរបស់ឯកឧត្តមអភិបាលខេត្តនៅក្នុងការដឹកនាំ គ្រប់គ្រង ក៏ដូចជាការដោះស្រាយបញ្ហានានា ដែលកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខេត្តបាត់ដំបង។ ឯកឧត្តមបានឱ្យក្រុមការងារដឹងថា នៅពេលដែលឯកឧត្តមបានទទួលសំណើ សំណូមពរ ពីប្រជាពលរដ្ឋ ឬពីធុរជន អង្គការសង្គមស៊ីវិលដទៃទៀតក្តី ឯកឧត្តមតែងតែ "ព្យាយាមចុះជួបផ្ទាល់ជាមួយប្រជាពលរដ្ឋ ឬទៅមើលដោយផ្ទាល់នៅទីតាំងដែលមានបញ្ហា" ក្នុងគោលបំណងសិក្សាឈ្វេងយល់អំពីបញ្ហាឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលដោះស្រាយឱ្យចំបញ្ហា និងមានប្រសិទ្ធភាព។ ពាក់ព័ន្ធចំណុចនេះ ប្រជាពលរដ្ឋ អាជីវករ សិស្ស និស្សិត ដែលក្រុមការងារបានចុះជួបសម្ភាសន៍ ក៏បានលើកសរសើរ



សកម្មភាពចុះអង្កេតមូលដ្ឋាន

ផងដែរថា ឯកឧត្តមអភិបាលខេត្តមានការទទួលខុសត្រូវខ្ពស់ រួមសុខទុក្ខជាមួយប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានទាន់ពេលវេលា។ ឯកឧត្តមថែមទាំងផ្តល់លេខទូរស័ព្ទរបស់ខ្លួនផ្ទាល់ ដើម្បីប្រជាពលរដ្ឋអាចទាក់ទងនៅពេលមានការចាំបាច់ទៀតផង។

ដោយឡែក ចំពោះការឆ្លើយតបទៅនឹងសំណើសំណូមពររបស់ធុរជន វិនិយោគិន ឬអង្គការសង្គមស៊ីវិល ឯកឧត្តមក៏នៅតែប្រកាន់គោលការណ៍ចុះទៅដល់ទីតាំងផ្ទាល់ដូចគ្នា ដើម្បីរិះរកមធ្យោបាយជួយសម្រួលដល់ការលំបាករបស់អ្នកទាំងនោះ ដែលកាយវិការនេះបានធ្វើឱ្យធុរជន វិនិយោគិន និងអង្គការសង្គមស៊ីវិលមានភាពកក់ក្តៅ និងរីករាយក្នុងការប្រកបមុខរបរ ក៏ដូចជាការបំពេញការងារនៅក្នុងខេត្តបាត់ដំបង ដែលជាហេតុធ្វើឱ្យខេត្តបាត់ដំបងទាក់ទាញបានការវិនិយោគ និងការចូលរួមរបស់អង្គការសង្គមស៊ីវិលកាន់តែច្រើនឡើងជាលំដាប់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងខេត្តបាត់ដំបង។

ក្រៅពីការចូលរួមដោះស្រាយដោយផ្ទាល់នូវបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ធុរជន វិនិយោគិន និងអង្គការសង្គមស៊ីវិល មន្ត្រីរាជការនៅសាលាខេត្តបាត់ដំបងដែលក្រុមការងារបានជួបសម្ភាសន៍បានលើកឡើងថា ឯកឧត្តមអភិបាលខេត្តតែងតែព្យាយាមចូលរួមអនុវត្តផ្ទាល់ជាមួយយើងទាំងអស់គ្នាដោយមិនគ្រាន់តែដាក់បញ្ហាឱ្យសហការីធ្វើប៉ុណ្ណោះទេ ក្នុងនោះមានដូចជា ការចូលរួមរើសសំរាមនៅតាមទីសាធារណៈ ដើម្បីលើកកម្ពស់សោភ័ណភាពទីក្រុងបាត់ដំបង និងការចូលរួមធ្វើអនាម័យ រក្សាសណ្តាប់ធ្នាប់នៅក្នុងផ្សារលក់ដូរជាដើម។ ជារួម "ការចុះផ្ទាល់" របស់ឯកឧត្តមឆ្លុះបញ្ចាំងឱ្យឃើញពី "ភាពសាមញ្ញ" នៅក្នុងសិល្បវិធីនៃការដឹកនាំ គ្រប់គ្រងរបស់ឯកឧត្តម។



សកម្មភាពចុះអង្កេតមូលដ្ឋាន

ក្រៅពីកិច្ចការងារខាងលើ ចំណុចពិសេសមួយទៀតរបស់ឯកឧត្តមអភិបាលខេត្តគឺការតាមដាននូវរាល់សកម្មភាពដំណោះស្រាយដែលបានដាក់ចេញដើម្បីឈ្វេងយល់អំពីលទ្ធផល ក៏ដូចជាបញ្ហាប្រឈមនូវការអនុវត្តកិច្ចការទាំងនោះ។ ជាក់ស្តែងឯកឧត្តមអភិបាលខេត្តតែងតែចុះសង្កេតជាប្រចាំដោយខ្លួនឯងផ្ទាល់ នៅតាមទីសាធារណៈមិនថាថ្ងៃឬយប់ឡើយ ដើម្បីធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ និងសោភ័ណភាពទីក្រុង ស្របតាមទស្សនៈរបស់ឯកឧត្តមដែលបាន សង្កត់ធ្ងន់ថា "**ពេលថ្ងៃត្រូវតែស្អាត មានសោភ័ណភាព សណ្តាប់ធ្នាប់ល្អ ពេលយប់ត្រូវតែមានសុវត្ថិភាព មានភ្លើងបំភ្លឺ**" ។

សរុបមក ការដឹកនាំ គ្រប់គ្រងដោយឈរលើគោលការណ៍នៃកិច្ចសហការ ការបើកទូលាយ និងការចុះផ្ទាល់ ព្រមទាំងការតាមដាន និងភាពសាមញ្ញតែម៉ឺងម៉ាត់ក្នុងការងាររបស់ឯកឧត្តម **ច័ន្ទ សុផល** អភិបាលខេត្តបាត់ដំបង បាននាំមកនូវការសាទរ និងការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋនៅក្នុងខេត្តបាត់ដំបង ក៏ដូចជាមជ្ឈដ្ឋានដទៃទៀត ព្រមទាំងបាននាំមកនូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើនទាំងលើផ្នែកសេដ្ឋកិច្ច និងសង្គមដែលជាការរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍខេត្តបាត់ដំបងឱ្យក្លាយជាខេត្តមួយ "មានការអភិវឌ្ឍប្រកបដោយនិរន្តរភាព សមភាព សមធម៌លើគ្រប់វិស័យ និងមានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ល្អ ធានាបាននូវការទាក់ទាញវិនិយោគិន និងអ្នកទេសចរមកកាន់ខេត្តបាត់ដំបងកាន់តែច្រើនឡើង" ដែលនេះជាចក្ខុវិស័យកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ រយៈពេលប្រាំឆ្នាំ (២០១៥-២០១៩) របស់ខេត្តបាត់ដំបង៕